ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងពាណិជ្ជកម្ម
លេខ ០៩៦១ ព.ណ.អវង

ថ្ងៃសុក្រ ២កើត ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៦

# សេចក្តីជូនដំណឹង
## ស្តីពីថ្លៃលក់រាយប្រេងឥន្ធនៈនៅតាមស្ថានីយ
## សម្រាប់ការអនុវត្តចាប់ពីថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៦

- យោងប្រកាសអន្តរក្រសួងលេខ០០៨៣ ពណ. អវង.ប្រក ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងក្រសួងរ៉ែ និងថាមពល ស្តីពីការកំណត់រូបមន្តសម្រាប់កែសម្រួលថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជា
- យោងលើការព្រមព្រៀង លើរូបមន្តកំណត់តម្លៃជាមួយក្រុមហ៊ុនប្រេងឥន្ធនៈដែលប្រកបអាជីវកម្មនៅកម្ពុជា
- យោងការប្រែប្រួលនៃតម្លៃប្រេងឥន្ធនៈលើទីផ្សារក្នុងតំបន់និងអន្តរជាតិ

រាជរដ្ឋាភិបាលបាន **១.** បន្តបញ្ចុះចំនួន **៦,៥សេនដុល្លារ/លីត្រ** ក្នុងគោលបំណងជួយសម្រួលដល់ជីវភាពរបស់ប្រជាពលរដ្ឋ **២. បន្តបញ្ចុះ ១សេនដុល្លារ/លីត្របន្ថែមទៀត** ដោយសារថ្លៃប្រេងសាំងអន្តរជាតិឡើងលើសពី ៩០ដុល្លារ/បារ៉ែល និងប្រេងម៉ាស៊ូតអន្តរជាតិឡើងលើស ១០០ដុល្លារ/បារ៉ែល **៣. ពន្ធគយ ០ (សូន្យ) ដុល្លារ** និង **៤.** ផ្អែកតាមសភាពការណ៍ និងថ្លៃប្រេងឥន្ធនៈបន្តកើនឡើងនៅទីផ្សារអន្តរជាតិ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានសម្រេច **បញ្ចុះអាករបន្ថែមលើប្រេងសាំង និងប្រេងម៉ាស៊ូតមក ០ (សូន្យ) ដុល្លារ, បញ្ចុះអាករពិសេសលើប្រេងម៉ាស៊ូត ពី ៤% មក 0%** និង **បញ្ចុះអាករលើតម្លៃបន្ថែមលើប្រេងសាំង និងប្រេងម៉ាស៊ូតពី ១០% មក ៤% ដោយរាជរដ្ឋាភិបាលទទួលបន្ទុកជំនួសចំនួន ៦%។**

ដូច្នេះថ្លៃលក់រាយប្រេងឥន្ធនៈត្រូវអនុវត្ត **ចាប់ពីថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៦ រហូតដល់ថ្ងៃជូនដំណឹងបន្ទាប់** គឺត្រូវលក់ **៥ ៤០០ រៀល/លីត្រ** សម្រាប់ប្រេងសាំងធម្មតា (Gasoline 92) និង **៦ ៧០០ រៀល/លីត្រ** សម្រាប់ប្រេងម៉ាស៊ូត (Gasoil 10ppm)។

### តារាងថ្លៃលក់រាយប្រេងឥន្ធនៈនៅលើទីផ្សារកម្ពុជា

| ល.រ | អធិប្បាយ | ប្រេងសាំងធម្មតា/លីត្រ Gasoline 92 | ប្រេងម៉ាស៊ូត/លីត្រ Gasoil 10ppm |
|---|---|---|---|
| ១ | ថ្លៃប្រេងអន្តរជាតិជាមធ្យម (Average MOPS) | ០,៩០២៧ ដុល្លារ | ១,៣០៣១ ដុល្លារ |
| ២ | **ពន្ធ៖** | **០,១៥៧១ ដុល្លារ** | **០,០០០០ ដុល្លារ** |
| | ពន្ធគយ | **០,០០០០ ដុល្លារ** | **០,០០០០ ដុល្លារ** |
| | អាករបន្ថែម | **០,០០០០ ដុល្លារ** | **០,០០០០ ដុល្លារ** |
| | អាករពិសេស | **០,១៥៧១ ដុល្លារ** | **០,០០០០ ដុល្លារ** |
| ៣ | **បុព្វលាភ (Premium)** | **០,២០ ដុល្លារ** | **០,២៣ ដុល្លារ** |
| ៤ | **អាករលើតម្លៃបន្ថែម (បញ្ចុះពី ១០% មក ៤%)** | **០,០៥០៤ ដុល្លារ** | **០,០៦១៣ ដុល្លារ** |
| ៥ | **ថ្លៃលក់រាយ/លីត្រ (គិតជាដុល្លារ)** | ១,៣១០២ ដុល្លារ | ១,៥៩៤៤ ដុល្លារ |
| ៦ | **ថ្លៃជានិរន្តរភាពនៃការផ្គត់ផ្គង់ (ដោយគិតបញ្ចូលទាំងថ្លៃដឹកជញ្ជូន និងសោហ៊ុយធានារ៉ាប់រងដែលក្រុមហ៊ុនត្រូវទទួលបន្ទុក)** | **០,០៤៨០ ដុល្លារ** | **០,០៨៥០ ដុល្លារ** |
| ៧ | **ក្រុមហ៊ុនប្រេងឥន្ធនៈបញ្ចុះតម្លៃ** | ០,០១ ដុល្លារ | ០,០១ ដុល្លារ |
| ៨ | **ថ្លៃដែលត្រូវដាក់លក់រាយ/លីត្រ (គិតជាដុល្លារ)** | **១,៣៥ ដុល្លារ** | **១,៦៧ ដុល្លារ** |
| ៩ | **ថ្លៃដែលត្រូវដាក់លក់រាយ/លីត្រ (គិតជារៀល)** | **៥ ៤០០ រៀល** | **៦ ៧០០ រៀល** |

**សម្គាល់៖** - ថ្លៃប្រេងឥន្ធនៈមុនការបញ្ចុះអាករបន្ថែម, អាករពិសេស និងអាករលើតម្លៃបន្ថែម៖ **ប្រេងសាំង ៥ ៦០០ រៀល/លីត្រ និងប្រេងម៉ាស៊ូត ៧ ០០០ រៀល/លីត្រ។**
- អត្រាប្តូរប្រាក់ផ្លូវការ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៦ ដែលស្មើនឹង ៤ ០១១រៀល/ដុល្លារអាម៉េរិក។
- ថ្លៃលក់រាយប្រេងឥន្ធនៈនៅកម្ពុជាដែលបានគណនា និងបង្ហាញខាងលើ គឺផ្អែកលើតម្លៃប្រេងឥន្ធនៈដែលបានប្រែប្រួលនៅលើទីផ្សារអន្តរជាតិ ស្របតាមប្រកាសរួម ដូចបានយោងខាងដើម។ បណ្តាស្ថានីយលក់រាយប្រេងឥន្ធនៈនៅកម្ពុជា អាចលក់ប្រេងក្នុងតម្លៃណាមួយ ដែលទាបជាងថ្លៃដែលបានគណនាខាងលើ តាមការប្រកួតប្រជែងជាក់ស្តែងនៃទីផ្សារនៅកម្ពុជា។

អាស្រ័យហេតុនេះ សូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន និងសូមគ្រប់ស្ថានីយលក់រាយប្រេងឥន្ធនៈទាំងអស់ប្រតិបត្តិចាប់ពី **ម៉ោង ១២:០០ថ្ងៃត្រង់ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៦។**